# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ ក្រោមប្រធានបទ ព្រះអតីតព្រះមហាក្សត្រខ្មែរព្រះករុណាសម្តេចព្រះនរោត្តម-សីហនុចែកអំណោយដល់អ្នកក្រីក្រខ្មែរ

web site: www.hoksavann,org

ថ្ងៃទី២៨ តុលា ២០០៦

អស់រយ:កាលជាច្រើនខែ មុនព្រះអង្គយាងទៅកាន់ប្រទេសចិនប្រជាមានិតុ ដើម្បីឲ្យវេជ្ជបណ្ឌិតចិនពិនិត្យព្រះសុខភាព ព្រះករុណាសម្តេចនរោត្តម-សីហនុព្រះអតីតព្រះមហាក្សត្រប្រទេសកម្ពុជា បានចែកអំណោយដល់អ្នកក្រីក្រខ្មែរ ដោយជ្រើសរើសអ្នកក្របំផុតនៅតាមខេត្តនានានៃប្រទេសកម្ពុជា ។ បន្ទាប់ពីបានផ្តល់ភោជនាហារឲ្យអ្នកក្រីក្រទាំងនោះទទួលទានឆ្អែតស្កប់ស្កល់ហើយ បានវេចខ្ចប់ចំណីអាហារទទួលទានតាមផ្លូវទៀត ។ ជាមួយគ្នានោះ ក៏បានធ្វើព្រះរាជអំណោយជាស្បៀងទុកទទួលទានបានចំនួនពីរបីអាទិត្យដែរ បន្ទាប់ពីត្រឡប់ទៅគេហដ្ឋានវិញ ។ មុននឹងជូនដំណើរត្រឡប់ទៅវិញតាមរថយន្ត ព្រះអតីតព្រះមហាក្សត្រខ្មែរមានព្រះបន្ទូលយ៉ាងខ្លីសួរសុខទុក្ខជនរួមជាតិទាំងនោះ ជាមួយនិងការជូនពរសព្វសាធុការផង ។ នេះជាសវនាការសួរសុខទុក្ខប្រជារាស្ត្រដោយផ្ទាល់របស់ព្រះអតីតព្រះមហាក្សត្រខ្មែរ ដែលព្រះអង្គក៏ធ្លាប់បានធ្វើពីមុនមកដែរ ។

ការផ្តល់អំណោយជួយរំលែកទុក្ខដល់ប្រជារាស្ត្រក្រីក្របំផុតរបស់ព្រះអតីតព្រះមហាក្សត្រខ្មែរ ជាអំពើកុសលជួយរំលែកទុក្ខបានតែមួយរយ:ពេលខ្លីប៉ុណ្ណោះ ឧបមាអំណោយនេះឲ្យពួកគេទទួលទានបានតែចំនួនមួយខែ ចុះមួយឆ្នាំមាន១២ខែ និងឆ្នាំបន្តទៅទៀតបានអ្វីទទួលទាន ហើយប្រជាពលរដ្ឋខ្មែរក្រីក្ររាប់លាននាក់ទៀត ដែលព្រះករុណាពុំបានផ្តល់អំណោយនោះ តើបានអ្វីទទួលទាន ? ។ ដូច្នេះជាការចាំបាច់ បើព្រះករុណាមានព្រះបំណងចង់ដោះស្រាយភាពក្រីក្ររបស់ប្រជាពលរដ្ឋខ្មែរពិតមែន សូមព្រះករុណាមេត្តាអំពាវនាវដល់រាជរដ្ឋាភិបាលខ្មែរ ឲ្យបំបាត់អំពើពុករលួយ បំបាត់ការកាប់ឈើដោយខុសច្បាប់ បញ្ឈប់ការរំលោភយកដីប្រជាពលរដ្ឋ

ពីអ្នកមានអំណាច ។ មួយទៀត បើប្រជាពលរដ្ឋគ្មានដីស្រែចំការ គ្មានគោក្របី គ្មាន
នង្គ័លរនាស់ ត្រូវតែរកជូនប្រជាពលរដ្ឋប្រកបមុខរបរកសិកម្ម ដែលប្រជាពលរដ្ឋ
ភាគច្រើន បានប្រកបមុខរបរនេះជាប្រពៃណី ។ នេះជាដំណោះស្រាយដល់ឫសគ
ល់ ដោយរកមធ្យោបាយជូនប្រជាពលរដ្ឋ ឲ្យប្រកបមុខរបរដោយខ្លួនឯង ។ ឧបមា
ថា គេឲ្យផ្លែស្វាយមួយទទួលទានតែម្តងក៏អស់ទៅ ប៉ុន្តែបើគេឲ្យគ្រាប់យកទៅដាំវិ-
ញ លុះដុះជាដើមមានផ្លែបេះរាប់ឆ្នាំ ។ ឯការចែកអំណោយនោះ គ្រាន់តែជាជំនួយ
បណ្តោះអាសន្នក្នុងភាពអាសន្នប៉ុណ្ណោះ ពុំមែនជាជំនួយបំបាត់ភាពក្រីក្រឡើយ ។
អ្នកខ្លះចោទថា ជំនួយខ្លះគ្រាន់តែជាការធ្វើប្រជាភិថុតិរបស់អ្នកកាន់អំណាច ដើម្បីឲ្យ
ប្រជាពលរដ្ឋស្រឡាញ់ចូលចិត្តប៉ុណ្ណោះ ។ ចំពោះរាជរដ្ឋាភិបាលខ្មែរ ដែលទទួល
ប្រាក់ខែពីរដ្ឋ មានភារកិច្ចធ្វើការបំរើប្រជាពលរដ្ឋ ។ ថវិកាកសាងជាតិកើតចេញមក
ពីពន្ធដារ ដែលប្រជាពលរដ្ឋបង់ជូនរដ្ឋ និងមួយភាគទៀតចេញមកពីកម្ចីនិងជំនួយ
បរទេស ឥឡូវនេះ គេឮសូរតាមវិទ្យុនិងទូរទស្សន៍រដ្ឋថា ស្ទើរតែគ្រប់សំណង់ទាំង
អស់គឺនាយករដ្ឋមន្ត្រីជាអ្នកកសាង ត្រង់ថវិកាដែលយកមកកសាងនោះបានមកពី
ណាគេពុំនិយាយឡើយ ហើយគ្រប់ពិធីសម្ពោធគេតែងពោលថា ប្រធានសភា ប្រ-
ធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីបច្ចុប្បន្ននេះ តែងតែគិតពីសុខទុក្ខរបស់បងប្អូន
ណាស់ ដែលផ្ទុយពីប្រទេសដទៃ ដូចសហរដ្ឋអាមេរិក គ្រប់ការកសាងទាំងអស់គេ
ពុំដែលថា ប្រធានាធិបតីសហរដ្ឋអាមេរិកជាអ្នកកសាងឡើយ ។ ដូច្នេះបញ្ជាក់ថា អ្ន
កកាន់អំណាចខ្មែរ បានពោលបន្លំក្នុងការកសាងជាថវិការបស់ជាតិ ឲ្យប្រជាពលរដ្ឋ
អ្នកស្តាប់យល់ថាជាថវិការបស់នាយករដ្ឋមន្ត្រីផ្ទាល់ ដើម្បីឲ្យប្រជាពលរដ្ឋដឹងគុណ
។ ដើម្បីកុំឲ្យភ័ន្តច្រឡំត្រូវពោលទៅតាមការពិត តើថវិការដែលយកមកកសាងជាតិ
នោះ បានមកពីណាខ្លះ ។

ចំពោះព្រះអតីតព្រះមហាក្សត្រខ្មែរមានព្រះជន្មកាន់តែចាស់ហើយ សូមធ្វើសំ
ណូមពរគួរឈប់រាំច្រៀងទៀតទៅ កុំប្រណាំងប្រជែងជាមួយអ្នកចំរៀងបុរសស្ត្រី
ក្មេងៗ មិនឈ្នះគេទេ ព្រោះកម្លាំងខ្សោយ សម្លេងមនុស្សចាស់មិនសូវពិរោះ ដូច
គេក្មេងៗទេ ។ ការរីករាយសប្បាយក្នុងកាមគុណ តាំងពីព្រះជន្មក្មេងមក ល្មមឈប់
ហើយ ក្នុងវ័យចាស់ជរា ត្រូវស្វែងរកធម៌អាថ៌ ដើម្បីសេចក្តីសុខស្ងប់តាមពាក្យ
ប្រៀនប្រដៅរបស់ព្រះពុទ្ធវិញ ។ គួរតែធ្វើគំរូល្អសំរាប់ជាតិ គួរតែដឹកនាំប្រជាពលរដ្ឋ
ខ្មែរទៅរកសីលធម៌ សុំដឹកនាំប្រជាពលរដ្ឋទៅរកតែកាមគុណរូបសម្លេងដែលជាអ
បាយមុខ ដែលជាបុព្វហេតុមួយនាំឲ្យកើតអំពើហឹង្សា ព្រោះព្រះករុណាពុំមែនជាមនុ
ស្សធម្មតា គឺជាអ្នកដឹកនាំខ្មែរជាងកន្លះសតវត្សរ៍ ។៚

❑ ❑

❑